CITY OF LONG BEACH

Health and Human Services

2525 Grand Avenue, Long Beach, CA 90815

(562) 570-4000 ទូរសារ (562) 570-4049

# សេចក្តីជូនដំណឹងអំពីការអនុវត្តចំពោះឯកជនភាព

**សេចក្តីជូនដំណឹងនេះរៀបរាប់ថាតើព័ត៌មានផ្ទាល់ខ្លួន និងព័ត៌មានវេជ្ជសាស្ត្រអំពីអ្នកអាចត្រូវបានប្រើ និងបញ្ចេញដូចម្តេចខ្លះ ហើយអ្នកអាចចូលមើលព័ត៌មាននេះរបៀបណា។ សូមត្រួតពិនិត្យសេចក្តីជូនដំណឹងនេះដោយយកចិត្តទុកដាក់។**

សេចក្តីជូនដំណឹងអំពីការអនុវត្តចំពោះឯកជនភាពនេះរៀបរាប់ថាតើយើងអាចប្រើ និងបញ្ចេញព័ត៌មានដែលត្រូវបានការពារ (PHI) របស់អ្នកដូចម្តេចខ្លះដើម្បីធ្វើការព្យាបាល ទូទាត់ប្រាក់ ឬប្រតិបត្តិការថែទាំសុខភាព (TPO) និងក្នុងគោលបំណងផ្សេងទៀតដែលអនុញ្ញាត ឬតម្រូវដោយច្បាប់។ វាក៏រៀបរាប់អំពីសិទ្ធិរបស់អ្នកក្នុងការចូលមើល និងគ្រប់គ្រងព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នកផងដែរ។ "ព័ត៌មានដែលត្រូវបានការពារ" គឺជាព័ត៌មានអំពីអ្នក រួមទាំងព័ត៌មានប្រជាសាស្ត្រ ដែលអាចបញ្ជាក់អត្តសញ្ញាណរបស់អ្នក និងពាក់ព័ន្ធនឹងបញ្ហាសុខភាពផ្លូវកាយឬផ្លូវចិត្ត ព្រមទាំងសេវាកម្មថែទាំសុខភាពដែលពាក់ព័ន្ធនាពេលកន្លងមក បច្ចុប្បន្ន ឬអនាគតរបស់អ្នក។

**ការធ្វើបច្ចុប្បន្នភាពថ្មីៗនេះទៅលើវិធានស្តីពីឯកជនភាពនៃច្បាប់ស្តីពីទំនួលខុសត្រូវ និងចល័តភាពនៃធានារ៉ាប់រងសុខភាព (Health Insurance Portability and Accountability Act, HIPPA)**

ឆ្លើយតបទៅនឹងការកែប្រែច្បាប់ និងបទប្បញ្ញត្តិថ្មីៗនេះ រួមទាំងការធ្វើបច្ចុប្បន្នភាពដើម្បីជួយដល់សុខភាពបន្តពូជ និងដោះស្រាយសំណើដែលលើកឡើងនៅក្នុងសេចក្តីជូនដំណឹងអំពីការតាក់តែងច្បាប់ដែលបានស្នើសម្រាប់ការរក្សាសម្ងាត់នូវកំណត់ត្រាអ្នកជំងឺ ("NPRM ផ្នែកទី 2") អំពីបញ្ហាសុខភាពដោយសារការប្រើសារធាតុញៀន (SUD) តាមការតម្រូវដោយ ឬស្របតាមច្បាប់ស្តីពីជំនួយ ជំនួយសង្គ្រោះ និងសន្តិសុខសេដ្ឋកិច្ចទាក់ទងនឹងវីរុសកូរ៉ូណា (CARES) ឆ្នាំ 2020 យើងបានធ្វើបច្ចុប្បន្នភាពការអនុវត្តចំពោះឯកជនភាពរបស់យើងដូចខាងក្រោម៖

## <u>ការប្រើ និងការបញ្ចេញព័ត៌មានដែលត្រូវបានការពារ (PHI)</u>

ព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នកអាចត្រូវបានប្រើ និងបញ្ចេញដោយគ្រូពេទ្យ បុគ្គលិកការិយាល័យរបស់យើង និងអ្នកផ្សេងទៀតក្រៅពីការិយាល័យរបស់យើងដែលពាក់ព័ន្ធនឹងការថែទាំ និងការព្យាបាលរបស់អ្នកក្នុងគោលបំណងផ្តល់សេវាថែទាំសុខភាពជូនអ្នក ទូទាត់វិក្កយបត្រថែទាំសុខភាពរបស់អ្នក ជួយដល់ប្រតិបត្តិការអនុវត្តន៍របស់គ្រូពេទ្យ និងការប្រើប្រាស់ផ្សេងទៀតដែលអនុញ្ញាតឬតម្រូវដោយច្បាប់។

**ការព្យាបាល៖** យើងនឹងប្រើ និងបញ្ចេញព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នកដើម្បីផ្តល់ សម្របសម្រួល ឬចាត់ចែងសេវាកម្មថែទាំសុខភាពនិងសេវាកម្មដែលពាក់ព័ន្ធ។ ចំណុចនេះរួមបញ្ចូលទាំងការសម្របសម្រួលឬការចាត់ចែងសេវាកម្មថែទាំសុខភាពរបស់អ្នកជាមួយភាគីទីបីផងដែរ។ ឧទាហរណ៍ ព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នកអាចផ្តល់ឱ្យគ្រូពេទ្យដែលអ្នកត្រូវបានណែនាំទៅជួប ដើម្បីប្រាកដថាគ្រូពេទ្យនោះមានព័ត៌មានដែលចាំបាច់ដើម្បីធ្វើរោគវិនិច្ឆ័យឬព្យាបាលអ្នក។

**ការទូទាត់ប្រាក់៖**
ព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នកនឹងត្រូវបានប្រើតាមការចាំបាច់ដើម្បីទទួលប្រាក់ទូទាត់ថ្លៃសេវាកម្មថែទាំសុខភាពរបស់អ្នក។ ឧទាហរណ៍ ការទទួលបានការយល់ព្រមឱ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យអាចនឹងតម្រូវឱ្យបញ្ចេញព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នកទៅឱ្យគម្រោងសុខភាពដើម្បីទទួលបានការយល់ព្រមឱ្យចូលព្យាបាលនៅមន្ទីរពេទ្យ។

**ប្រតិបត្តិការថែទាំសុខភាព៖** យើងអាចប្រើ ឬបញ្ចេញព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នកតាមការចាំបាច់ដើម្បីទ្រទ្រង់សកម្មភាពអាជីវកម្មនៃការព្យាបាលដោយគ្រូពេទ្យរបស់អ្នក។ សកម្មភាពទាំងនេះរួមមានជាអាទិ៍ ការវាយតម្លៃគុណភាព ការវាយតម្លៃបុគ្គលិក ការបណ្តុះបណ្តាលសិស្សពេទ្យ ការផ្តល់អាជ្ញាប័ណ្ណ ការរៃអង្គាសនិងការធ្វើឬរៀបចំសម្រាប់សកម្មភាពអាជីវកម្មផ្សេងទៀត។ ឧទាហរណ៍ យើងអាចបញ្ចេញព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នកឱ្យសិស្សពេទ្យដែលព្យាបាលអ្នកជំងឺនៅការិយាល័យរបស់យើង។ បន្ថែមពីនេះ យើងអាចប្រើបញ្ជីចុះឈ្មោះចូលនៅតុចុះឈ្មោះ ដែលអ្នកនឹងត្រូវបានស្នើឱ្យចុះឈ្មោះ និងបញ្ជាក់គ្រូពេទ្យរបស់អ្នក។ យើងក៏អាចហៅឈ្មោះរបស់អ្នកនៅក្នុងបន្ទប់រង់ចាំផងដែរនៅពេលគ្រូពេទ្យរបស់អ្នកត្រៀមរួចរាល់ក្នុងការជួបអ្នក។ យើងអាចប្រើ ឬបញ្ចេញព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នកតាមការចាំបាច់ ដើម្បីទាក់ទងទៅអ្នកក្នុងបំណងរំលឹកអ្នកអំពីការណាត់ជួប និងប្រាប់អ្នកអំពីជម្រើសព្យាបាលឬសេវាកម្មនិងអត្ថប្រយោជន៍ពាក់ព័ន្ធនឹងសុខភាពផ្សេងទៀតដែលអ្នកប្រហែលជាចាប់អារម្មណ៍។

## <u>ការប្រើប្រាស់និងការបញ្ចេញព័ត៌មានជាក់លាក់</u>

**ព័ត៌មានអំពីសុខភាពបន្តពូជ៖** យោងតាមវិធានស្តីពីឯកជនភាពនៃច្បាប់ HIPAA ដែលបានធ្វើបច្ចុប្បន្នភាព យើងប្តេជ្ញាធានារក្សាការសម្ងាត់ និងសុវត្ថិភាពចំពោះព័ត៌មានអំពីសុខភាពបន្តពូជរបស់អ្នក។ ចំណុចនេះរួមបញ្ចូលព័ត៌មានពាក់ព័ន្ធនឹងការធ្វើផែនការគ្រួសារ ការមានផ្ទៃពោះ ការពន្យារកំណើត ការព្យាបាលលទ្ធភាពមានកូននិងសេវាកម្មដែលពាក់ព័ន្ធផ្សេងទៀត។

**Health and Human Services**

CITY OF LONG BEACH

2525 Grand Avenue, Long Beach, CA 90815

(562) 570-4000 ទូរសារ (562) 570-4049

យើងនឹងមិនបញ្ចេញព័ត៌មាននេះដោយគ្មានការអនុញ្ញាតច្បាស់លាស់ពីអ្នកឡើយ លើកលែងតែមានការតម្រូវដោយច្បាប់ឬក្នុងកាលៈទេសៈជាក់លាក់ដូចជា៖

- **ទៅឱ្យអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក៖** ក្នុងគោលបំណងព្យាបាលដើម្បីធានាបន្តការថែទាំ។
- **ទៅឱ្យអាជ្ញាធរសុខភាពសាធារណៈ៖** ប្រសិនបើច្បាប់តម្រូវឱ្យរាយការណ៍អំពីសុខភាពសាធារណៈ។
- **ដើម្បីបង្ការគ្រោះថ្នាក់ធ្ងន់ធ្ងរ៖** ប្រសិនបើចាំបាច់ ដើម្បីបង្ការគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះសុខភាពឬសុវត្ថិភាព។

**កំណត់ត្រាអំពីបញ្ហាសុខភាពទាក់ទងនឹងការប្រើសារធាតុញៀន៖** អនុលោមតាមច្បាប់ CARES និង NPRM ផ្នែកទី 2 ដែលបានស្នើ យើងនឹងរក្សាការសម្ងាត់នូវកំណត់ត្រាព្យាបាលបញ្ហាសុខភាពដោយសារការប្រើសារធាតុញៀនរបស់អ្នក ហើយបញ្ចេញព័ត៌មាននេះដោយមានការយល់ព្រមពីអ្នកប៉ុណ្ណោះ លើកលែងតែមានការតម្រូវ ឬអនុញ្ញាតដោយច្បាប់។

យើងអាចប្រើ ឬបញ្ចេញព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នកក្នុងស្ថានភាពដូចខាងក្រោមដោយមិនចាំបាច់មានការអនុញ្ញាតពីអ្នក។ ស្ថានភាពទាំងនេះមានដូចជា តាមការតម្រូវដោយច្បាប់ បញ្ហាសុខភាពសាធារណៈតាមការតម្រូវដោយច្បាប់ ជំងឺឆ្លង ការគ្រប់គ្រងសុខភាព ការរំលោភបំពានឬការធ្វេសប្រហែស លក្ខខណ្ឌតម្រូវនៃការប្រើអាហារនិងឱសថ នីតិវិធីផ្លូវច្បាប់ ការអនុវត្តច្បាប់ អ្នកវិភាគសាកសព ពួកបូជាសព ក៏ដូចជាការបរិច្ចាគសរីរាង្គ ការស្រាវជ្រាវ សកម្មភាពឧក្រិដ្ឋកម្ម សកម្មភាពយោធានិងសន្តិសុខជាតិ ប្រាក់ទូទាត់សងអ្នកធ្វើការ ទណ្ឌិត ព្រមទាំងការប្រើប្រាស់ និងការបញ្ចេញព័ត៌មានដែលបានតម្រូវផ្សេងទៀត។

ស្របតាមច្បាប់ យើងត្រូវតែបញ្ចេញព័ត៌មានឱ្យអ្នកនៅពេលអ្នកស្នើសុំ។ យើងត្រូវតែបញ្ចេញព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នកផងដែរ នៅពេលតម្រូវដោយលេខាធិការនៃនាយកដ្ឋានសុខាភិបាល និងសេវាពលរដ្ឋ ដើម្បីស៊ើបអង្កេតឬកំណត់ថាយើងអនុលោមតាមលក្ខខណ្ឌតម្រូវក្រោមផ្នែក 164.500 ឬអត់។

ការប្រើ និងការបញ្ចេញព័ត៌មានដែលត្រូវបានអនុញ្ញាត និងតម្រូវផ្សេងទៀតនឹងធ្វើឡើងដោយមានការយល់ព្រម ការផ្តល់សិទ្ធិអនុញ្ញាត ឬឱកាសក្នុងការបដិសេធពីអ្នកប៉ុណ្ណោះ លើកលែងតែមានការតម្រូវដោយច្បាប់។ អ្នកអាចដកហូតការផ្តល់សិទ្ធិអនុញ្ញាតបានគ្រប់ពេលជាសំណេរ លើកលែងតែក្នុងករណីគ្រូពេទ្យរបស់អ្នក ឬការអនុវត្តរបស់គ្រូពេទ្យបានធ្វើសកម្មភាពដោយពឹងផ្អែកលើការប្រើ ឬការបញ្ចេញព័ត៌មានដែលបានបញ្ជាក់នៅក្នុងការផ្តល់សិទ្ធិអនុញ្ញាតនោះ។

**<u>សិទ្ធិរបស់អ្នក</u>**

ខាងក្រោមនេះគឺជាសេចក្តីថ្លែងស្តីពីសិទ្ធិរបស់អ្នកពាក់ព័ន្ធនឹងព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នក៖

**1. សិទ្ធិត្រួតពិនិត្យ និងចម្លង៖** អ្នកមានសិទ្ធិត្រួតពិនិត្យ និងចម្លងព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នក (អាចមានការគិតថ្លៃសេវា)។ ទោះយ៉ាងណា ស្របតាមច្បាប់សហព័ន្ធ អ្នកមិនអាចត្រួតពិនិត្យ ឬចម្លងកំណត់ត្រាដូចតទៅនេះ៖ កំណត់សម្គាល់ការព្យាបាលផ្លូវចិត្ត ព័ត៌មានដែលចងក្រងដោយរំពឹងក្នុងហេតុផលសមស្របថាមាន ឬត្រូវបានប្រើក្នុងនីតិវិធីឬវិធានការស៊ីវិល ឧក្រិដ្ឋកម្ម ឬរដ្ឋបាល ព័ត៌មានសុខភាពដែលត្រូវបានការពារដែលដាក់កំហិតដោយច្បាប់ ព័ត៌មានពាក់ព័ន្ធនឹងការស្រាវជ្រាវវេជ្ជសាស្ត្រដែលអ្នកបានយល់ព្រមចូលរួម ព័ត៌មានដែលបញ្ចេញទៅអាចបង្កគ្រោះថ្នាក់ឬបង្ករបួសដល់អ្នកឬអ្នកផ្សេងទៀត ឬព័ត៌មានដែលទទួលបានក្រោមការសន្យាថារក្សាសម្ងាត់។

**2. សិទ្ធិស្នើសុំការដាក់កំហិត៖** អ្នកមានសិទ្ធិស្នើសុំការដាក់កំហិត ឬដាក់ដែនកំណត់លើការប្រើ ឬបញ្ចេញព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នកក្នុងគោលបំណងព្យាបាល ទូទាត់ប្រាក់ ឬធ្វើប្រតិបត្តិការថែទាំសុខភាព។ អ្នកក៏អាចស្នើសុំកុំឱ្យបញ្ចេញព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នកទៅឱ្យសមាជិកគ្រួសារ ឬមិត្តភក្តិដែលអាចពាក់ព័ន្ធនឹងការថែទាំរបស់អ្នក ឬក្នុងគោលបំណងជូនដំណឹងដូចបានរៀបរាប់ក្នុងសេចក្តីជូនដំណឹងអំពីការអនុវត្តចំពោះឯកជនភាពនេះបានផងដែរ។ សំណើរបស់អ្នកត្រូវតែបញ្ជាក់អំពីការដាក់កំហិតច្បាស់លាស់ និងថាតើអ្នកចង់ឱ្យអនុវត្តការដាក់កំហិតនេះលើនរណា។ គ្រូពេទ្យរបស់អ្នកមិនត្រូវបានតម្រូវឱ្យយល់ព្រមតាមការដាក់កំហិតដែលអ្នកបានស្នើសុំទេ។

**3. សិទ្ធិប្រាស្រ័យទាក់ទងដោយរក្សាការសម្ងាត់៖** អ្នកមានសិទ្ធិស្នើសុំឱ្យយើងប្រាស្រ័យទាក់ទងជាមួយអ្នកអំពីបញ្ហាវេជ្ជសាស្ត្រក្នុងលក្ខណៈណាមួយ ឬនៅទីតាំងណាមួយជាក់លាក់។

**4. សិទ្ធិទទួលបានច្បាប់ចម្លងជាក្រដាស៖** អ្នកមានសិទ្ធិទទួលច្បាប់ចម្លងនៃសេចក្តីជូនដំណឹងនេះជាក្រដាសពីយើងបានតាមរយៈការស្នើសុំ ទោះជាអ្នកយល់ព្រមទទួលយកសេចក្តីជូនដំណឹងនេះតាមប្រព័ន្ធអេឡិចត្រូនិកហើយក៏ដោយ។

**5. សិទ្ធិស្នើសុំកែប្រែ៖** អ្នកមានសិទ្ធិស្នើសុំឱ្យយើងកែប្រែព័ត៌មានសុខភាពដែលត្រូវបានការពាររបស់អ្នក ប្រសិនបើអ្នកជឿជាក់ថាវាមិនត្រឹមត្រូវ ឬមិនពេញលេញ។ ប្រសិនបើយើងបដិសេធសំណើសុំឱ្យកែប្រែរបស់អ្នក នោះអ្នកមានសិទ្ធិដាក់សេចក្តីថ្លែងជំទាស់មកយើងបាន ហើយយើងអាចរៀបចំការឆ្លើយបដិសេធចំពោះសេចក្តីថ្លែងរបស់អ្នក។ យើងនឹងផ្តល់ជូនអ្នកមួយច្បាប់នៃការឆ្លើយបដិសេធនេះ។

**6. សិទ្ធិទទួលបានកំណត់ត្រានៃការបញ្ចេញព័ត៌មាន៖** អ្នកមានសិទ្ធិទទួលកំណត់ត្រានៃការបញ្ចេញព័ត៌មានទាំងអស់

2525 Grand Avenue, Long Beach, CA 90815

(562) 570-4000 ទូរសារ (562) 570-4049

លើកលែងតែការបញ្ចេញព័ត៌មានៈ ដែលស្របតាមការផ្ដល់សិទ្ធិអនុញ្ញាត ក្នុងគោលបំណងព្យាបាល ទូទាត់ប្រាក់ ឬប្រតិបត្តិការថែទាំសុខភាព មានការតម្រូវដោយច្បាប់ ដែលបានបញ្ចេញមុនថ្ងៃទី 14 ខែមេសា ឆ្នាំ 2003 ឬប្រាំមួយឆ្នាំមុនកាលបរិច្ឆេទនៃសំណើ។

**7. សិទ្ធិទទួលបានច្បាប់ចម្លងជាក្រដាសនៃសេចក្ដីជូនដំណឹងនេះៈ** អ្នកមានសិទ្ធិទទួលច្បាប់ចម្លងជាក្រដាសនៃសេចក្ដីជូនដំណឹងនេះពីយើង ទោះជាអ្នកយល់ព្រមទទួលសេចក្ដីជូនដំណឹងនេះតាមប្រព័ន្ធអេឡិចត្រូនិកហើយក៏ដោយ។

យើងរក្សាសិទ្ធិកែប្រែលក្ខខណ្ឌនៃសេចក្ដីជូនដំណឹងនេះ ហើយនឹងជូនដំណឹងទៅអ្នកអំពីការកែប្រែនេះនៅក្នុងការណាត់ជួបបន្ទាប់។ យើងក៏នឹងមានផ្ដល់ជូនច្បាប់ចម្លងនៃសេចក្ដីជូនដំណឹងថ្មីផងដែរ ប្រសិនបើអ្នកចង់បាន។

**<u>បណ្ដឹងតវ៉ា</u>**

អ្នកអាចដាក់បណ្ដឹងតវ៉ាមកយើង ឬដាក់បណ្ដឹងតវ៉ាទៅលេខាធិការនៃនាយកដ្ឋានសុខាភិបាល និងសេវាពលរដ្ឋបាន ប្រសិនបើអ្នកជឿជាក់ថាយើងបានបំពានសិទ្ធិឯកជនភាពរបស់អ្នក។ អ្នកអាចដាក់បណ្ដឹងតវ៉ាមកយើងដោយជូនដំណឹងទៅមន្ត្រីផ្នែកអនុលោមតាមច្បាប់ HIPAA របស់យើងអំពីបណ្ដឹងតវ៉ារបស់អ្នក។ យើងនឹងមិនសងសឹកលើអ្នកដោយសារការដាក់បណ្ដឹងតវ៉ាឡើយ។

ច្បាប់តម្រូវឱ្យយើងរក្សាឯកជនភាពរបស់បុគ្គល និងផ្ដល់ជូនបុគ្គលនូវសេចក្ដីជូនដំណឹងអំពីការអនុវត្តផ្នែកឯកជនភាព និងភារកិច្ចផ្លូវច្បាប់ពាក់ព័ន្ធនឹងព័ត៌មានសុខភាពដែលត្រូវបានការពារនេះ។ ច្បាប់ក៏តម្រូវឱ្យយើងគោរពតាមលក្ខខណ្ឌនៃសេចក្ដីជូនដំណឹងដែលមានសុពលភាពនាពេលបច្ចុប្បន្នផងដែរ។ ប្រសិនបើអ្នកមានសំណួរអំពីទម្រង់បែបបទនេះ សូមស្នើសុំជជែកជាមួយមន្ត្រីផ្នែកអនុលោមតាមច្បាប់ HIPAA របស់យើងតាមលេខទូរសព្ទ 562-570-4225។